រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០០

**សេចក្ដីសម្រេចលេខ ១៦ សសរ.**

**ស្ដីពីរូបសញ្ញា ក្រសួងការពារជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ៣៧/អនក្រ/បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

**ប្រការ ១ :** កំណត់រូបសញ្ញា និងនិយមន័យ នៃរូបសញ្ញារបស់ក្រសួងការពារជាតិដូចខាងក្រោម :

រូបសញ្ញារបស់ក្រសួងការពារជាតិ ត្រូវតំណាងដោយរង្វង់មូល នៅកណ្ដាលរង្វង់មូលមានរូបហនុមានទ្រង់គ្រឿង ផ្នែកខាងក្រោមរង្វង់មូលមានចារឹកអក្សរថា" ក្រសួងការពារជាតិ" លើរង្វង់មូលមានម្កុដលើម្កុដមានពន្លឺពណ្ណរង្សី ខាងក្រោមរង្វង់មូលទ្រដោយយុថ្កា មានសញ្ញាស្លាបសន្លឹងសងខាងរង្វង់ និងអមដោយកួរស្រូវព័ទ្ធជុំវិញរង្វង់ ។

- ពន្លឺពណ្ណរង្សី តំណាងឲ្យមសពិធរាជធម៌ នៃអង្គព្រះមហាក្សត្រ ។
- រូបម្កុដទ្រង់គ្រឿង តំណាងឲ្យជាតិ សាសនា ព្រះមហាក្សត្រ ។
- ក្បាច់ រំយោលតំណាងឲ្យការរក្សានូវប្រពៃណី និងខឿនវប្បធម៌ជាតិ ។
- ផ្កាករង្វង់ពណ៌ក្រហមភ្ជាប់ និងរំយោលសងខាងបញ្ជាក់ឲ្យឈ្មោះស្ថាប័នរបស់ក្រសួងការពារជាតិ ។
- រូបហនុមានទ្រង់គ្រឿង ដែលស្ដាំចង្អុលឆ្ពោះត្រង់ទៅមុខ ដៃឆ្វេងកាន់ព្រះខ័នសំដែងឫទ្ធិតំណាងឲ្យកងយោធពលខេមរភូមិន្ទ ជាមេទ័ព និងពលសេនាទ័ពជើងគោកដ៏មានឫទ្ធិ មានទឹកចិត្តភក្ដីភាពចំពោះមាតុភូមិ ការពារជាតិ សាសនា និងព្រះមហាក្សត្រ ។

- រូបសញ្ញាស្លាបគន្លឹងសងខាង តំណាងឲ្យកងទ័ពជើងអាកាស និងយុថ្កាតំណាងឲ្យកងទ័ពជើងទឹក ដែលប្រសូត្រចេញពីប្រជាជន ហ៊ានធ្វើពលីកម្ម ពុះពារជំនះគ្រប់ឧបសគ្គតូច-ធំមានឆន្ទៈមោះមុត ដើម្បីការពារឲ្យនូវឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពទឹកដី ដែនគោក ដែនទឹក ដែនកោះ និងដែនអាកាស រក្សាឲ្យភាពសុខដុមរម្យនារបស់ប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។
- ពួរស្រូវអមសងខាងព័ទ្ធជារង្វង់ បញ្ជាក់ការរួមចំណែកការបង្កបង្កើនផលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិ មានស្រូវជាដំណាំកសិកម្មដ៏សំខាន់ ដែលកងទ័ពយកចិត្តទុកដាក់បំផុតស្របនឹងពាក្យស្លោកថែងថា ៖ "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ" ។

ប្រការ ២ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រី

### សេចក្តីសម្រេច

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០០

**សេចក្តីសម្រេចលេខ ២០ សសរ.**

**ស្តីពីការចាត់តាំងកិច្ចមន្ត្រីមធ្យម**

**ជំនាន់សន្តិភាព ២**

***

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៩/៥០ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល